# ហាងលក់ស្បែកជើងរបស់អាប៊ូឡូ

ដោយ រេ ហ្គោឌ្រីប
ផ្អែកទៅលើដំណើររឿងពិត

« *'I am sorry' is not always easy to say* » ( Children's Songbook *ទំព័រ ៩៨* ) ។

មីហ្គែល បានបើកទ្វារចូលហាងលក់ស្បែកជើងរបស់អាប៊ូឡូ ( ហាងរបស់ជីតាគាត់ ) ។ គាត់ធុំក្លិនស្បែកដែលអាប៊ូឡូបានធ្វើការជាមួយ ។ វាជាក្លិនមួយដែលគាត់ចូលចិត្ត ។

« សួស្តី អាប៊ូឡូ ! »

អាប៊ូឡូកំពុងលុតជង្គង់ចុះ ហើយគូសដានជើងរបស់អតិថិជននៅលើក្រដាសមួយសន្លឹក ។ គាត់ពុំបានងើយមើលលើឡើយ ។ ត្រចៀករបស់អាប៊ូឡូពុំសូវល្អឡើយ ។

មីហ្គែលអង្គុយនៅលើកៅអីធ្វើការ ។ គាត់សម្លឹងមើលស្បែកដែលកាត់ដាក់គរលើគ្នា ។ គាត់ស្រមៃអំពីអ្វីដែលអាប៊ូឡូនឹងធ្វើជាមួយស្បែកនីមួយៗនោះ ដោយប្រើញញួរ និងដង្កាប់របស់គាត់ ។

ឧបករណ៍នោះរំឭកមីហ្គែលអំពីអ្វីផ្សេងទៀតដែលគាត់ស្រឡាញ់ ។ អាប៊ូឡូតែងតែឲ្យស្ករគ្រាប់ដល់គាត់ពេលមីហ្គែលជួយគាត់បោសសម្អាត ។

ប៉ុន្តែឥឡូវមីហ្គែលឃ្លានហើយ ! គាត់ដឹងថា គាត់មិនត្រូវយកនំញ៉ាំដោយពុំសូមឡើយ ប៉ុន្តែអាប៊ូឡូហាក់ដូចជាកំពុងរវល់មួយរយៈ ។ មីហ្គែលបានគិតថា « ប្រហែលជាខ្ញុំពុំបាច់ចាំទេ » ។

មីហ្គែលបានលូកដៃទៅក្រោមតុយកក្រឡកែវស្ករគ្រាប់ ។ ក្រឡកែវនោះមានស្ករគ្រាប់ពេញដែលគាត់ចូលចិត្ត — ផ្អែម និងហិរៗជាមួយនឹងម្សៅម្ទេស ! ពេលគាត់បើកក្រឡនោះ មីហ្គែលមានអារម្មណ៍មិនស្រណុកចិត្តឡើយ ។ ប៉ុន្តែមើលទៅស្ករគ្រាប់គួរឲ្យឆ្ងាញ់ណាស់ ។ គាត់បានប្រញាប់ដាក់វាចូលមាត់គាត់ភ្លាម ។

ភ្លាមនោះអតិថិជនបានចេញទៅ ។ អាប៊ូឡូបានលើកស្បែកមួយបន្ទះនោះឡើង ហើយជ្រលក់វាក្នុងទឹក ។ ការធ្វើបែបនេះជួយឲ្យស្បែកទន់ ហើយងាយនឹងធ្វើ ។

មីហ្គែលញ៉ាំស្ករគ្រាប់ដែលនៅសល់យ៉ាងលឿនតាមដែលគាត់អាចធ្វើបាន ។ បន្ទាប់មកគាត់បានដើរទៅរកអាប៊ូឡូ ។





*លោកតានិយាយថា « ចៅដឹងទេ យើងត្រូវតែក្លាយឲ្យកាន់តែដូចស្បែកជើងនេះ » ។*



អាប៊ូឡូនិយាយដោយញញឹមថា ៖ « សួស្តី ! តាសប្បាយចិត្តណាស់ដែលចៅមកមើលតា » ។

មីហ្គែលឱបអាប៊ូឡូ ។ គាត់បានរំពឹងថា អាប៊ូឡូ មិនដឹងថា គាត់បានញ៉ាំស្ករគ្រាប់អស់មួយឡើយ ។ មីហ្គែលបានធ្វើជាមិនព្រួយបារម្ភអ្វីឡើយ ។

មីហ្គែលបាននិយាយដោយចង្អុលទៅគំនរស្បែកថា « មើលទៅលោកតារវល់ណាស់ថ្ងៃនេះ ។ តើតាត្រូវការជំនួយទេ ? »

« បាទត្រូវការ ! តើចៅអាចជួយហុចអំបោះនោះឲ្យតាបានទេ ? »

មីហ្គែលបានឈោងទៅយកអំបោះដ៏វែងនោះ ។ គាត់ប្រើដៃទាំងពីររបស់គាត់ទាញអំបោះនោះ ។ វាពិបាកនឹងទាញមកជាងការគិត ។

អាប៊ូឡូបានសើចកក្អឹក

« ឱ វារឹងមាំណាស់ ។ វាត្រូវតែមាំ ដើម្បីវានៅជាប់រហូត » ។ អាប៊ូឡូបានទាញអំបោះដេរស្បែកនោះ ។ បន្ទាប់មកគាត់មានទឹកមុខដែលជួនកាលលោកយាយហៅថាទឹកមុខ « អាប៊ូឡូដ៏វាងវៃ » ។

អាប៊ូឡូនិយាយដោយងក់ក្បាលថា « ចៅដឹងទេ យើងត្រូវតែក្លាយឲ្យកាន់តែដូចស្បែកជើងនេះ » ។

មីហ្គែល បានខំសម្លឹងមើលស្បែកនោះយ៉ាងជិត ។ « ហឺ មែនឬ ? »

« មែនហើយ ។ យើងត្រូវបន្តរឹងមាំ ។ តាមរបៀបនោះ ការល្បួងរបស់សាតាំងពុំធ្វើឲ្យយើងវិនាសឡើយ » ។

ភ្លាមនោះមីហ្គែលបាននឹកចាំពីស្ករគ្រាប់ពណ៌ក្រហមនោះ ។ គាត់បានដឹងថាគាត់គួរតែប្រាប់អាប៊ូឡូអំពីវា ។

អាប៊ូឡូបានយកស្បែកជើងចាស់ចុះពីធ្នើរ ។ « ឃើញប្រហោងធំនេះដែរទេ ? »

ដៃរបស់មីហ្គែលប្រហែលជាអាចដាក់ត្រូវនឹងប្រហោងនោះ ។ « មែនហើយ ។

ពីមុនប្រហោងនេះនៅតូច ដែលអាចជួសជុលវាដោយងាយស្រួល ។ ប៉ុន្តែពួកគេបានរង់ចាំ ហើយឥឡូវវាពិបាកនឹងជួសជុលខ្លាំងណាស់ ។ ទម្លាប់អាក្រក់ និងការជ្រើសរើសអាក្រក់គឺដូចជាប្រហោងនោះដែរ ។ វាល្អបំផុតដើម្បីជួសជុលវាភ្លាមៗ » ។

អាប៊ូឡូ បានងក់ក្បាលម្តងទៀត ហើយទឹកមុខអាប៊ូឡូដ៏វាងវៃបានត្រឡប់មកជាការញញឹមវិញ ។ ពួកគេបានបន្តនិយាយគ្នាពេលអាប៊ូឡូកំពុងធ្វើការ ។ មីហ្គែលនៅតែបន្តគិតអំពីស្ករគ្រាប់ពណ៌ក្រហមនោះគ្រប់ពេល ។

ពេលអាប៊ូឡូបានបញ្ចប់ការងារ មីហ្គែលបានជួយបោសសម្អាតគាត់ ។ ក្រោយមកអាប៊ូឡូបានលូកដៃទៅយកក្រឡស្ករគ្រាប់របស់គាត់ ។

ទីបំផុត មីហ្គែលពុំអាចយកស្ករគ្រាប់បានទៀតឡើយ ។ គាត់បាននិយាយភ្លាមថា « ចៅបានយកស្ករគ្រាប់តាមួយរួចហើយ ! »

អាប៊ូឡូបានបិទក្រឡស្ករគ្រាប់វិញ ។ « តើចៅចង់និយាយថាម៉េច ? »

មីហ្គែលបានប្រាប់គាត់អំពីការយកស្ករគ្រាប់ដោយពុំបានសូម ។ « ចៅសូមទោស លោកតា ! ចៅសន្យាថា ចៅនឹងពុំធ្វើវាម្តងទៀតឡើយ ! »

អាប៊ូឡូបានឱបមីហ្គែលយ៉ាងណែន ។ មីហ្គែលមានអារម្មណ៍ *ធូរ* ជាងមុនច្រើនណាស់ ។

« អរគុណចៅដែលចៅមានភាពទៀងត្រង់ ។ វាសំខាន់ចំពោះតាជាងអ្វីៗទាំងអស់ » ។

នៅពេលដើរទៅផ្ទះវិញ មីហ្គែលមានអារម្មណ៍ដូចជាស្បែកជើងថ្មីមួយគូរបស់អាប៊ូឡូដែរ ។ រឹងមាំឲ្យអស់ពីសមត្ថភាព ហើយត្រៀមរួចជាស្រេចដើម្បីជីវិត ! ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



**អារម្មណ៍ល្អ**

ថ្ងៃមួយខ្ញុំ និងម្តាយខ្ញុំបានទៅបង់ថ្លៃទឹក ហើយបុរសម្នាក់នៅឈរខាងមុខយើងបានជ្រុះប្រាក់ទាំងអស់ដោយពុំដឹងខ្លួន ។ ខ្ញុំបានប្រញាប់រើស ហើយឲ្យប្រាក់នោះទៅគាត់វិញ ។ គាត់បាននិយាយថា « អរគុណខ្លាំងណាស់ » ហើយគាត់និយាយថា គាត់ពុំគិតថា ក្មេងដទៃទៀតនឹងធ្វើបែបនេះទេ ។ ខ្ញុំពិតជាមានអារម្មណ៍ល្អណាស់បន្ទាប់ពីរឿងនោះមក ។ ខ្ញុំនឹងចងចាំអារម្មណ៍ល្អនោះជានិច្ច ។

**ប្រាយអិនណា ស៊ី អាយុ ៩ ឆ្នាំ រដ្ឋ អៃដាហូ ស. រ. អា.**